**ភីលីព ៣:១២-២១**

**ការរត់ទៅមុខ**

**ការរំលឹក** នៅក្នុងភីលីព ៣:១-១១ យើងបានឃើញថា ដោយព្រោះ លោកប៉ុលបានរាប់ថាការស្គាល់ដល់ព្រះគ្រីស្ទ និង ការទទួលសេចក្តីសុចរិតដោយសារព្រះគ្រីស្ទ ប្រសើរជាងអ្វីៗទាំងអស់ ដូច្នេះគាត់សប្បាយរីករាយនឹងការដោះដូរទាំងអស់នេះណាស់ គឺគាត់ចាកចោលអ្វីៗដែលមនុស្សអួត និងរាប់អាន ដើម្បីវិលមកប្រកបក្នុងការរងទុក្ខជាមួយនឹងព្រះគ្រីស្ទ ព្រមទាំងសេចក្តីស្លាប់វិញផង។

ចូរអានភីលីព ៣:១២-២១

សូមអាន ៣:១២-១៤ ម្តងទៀត។

តើ ‹រង្វាន់› នៅក្នុងខ១៤គឺជាអ្វី?

តើអាកប្បកិរិយារបស់លោកប៉ុលនៅក្នុងខ១២-១៤គឺជាអ្វី?

**ការពន្យល់** លោកប៉ុលអាចគិតអំពីអ្វីទាំងអស់ដែលគាត់បានធ្វើពីមុនមក ប្រយោជន៍ដើម្បីនឹងបំរើដល់ព្រះគ្រីស្ទ។ អ្នកខ្លះប្រព្រឹត្តបែបនេះដែរ ហើយប្រហែលអួតអំពីសកម្មភាពរបស់គេផង។ ប៉ុន្តែលោកប៉ុលមានអាកប្បកិរិយាផ្ទុយពីនេះវិញ។ គាត់សម្រេចចិត្តថានឹង‹ភ្លេចសេចក្តី ទាំងប៉ុន្មាន ដែលកន្លងទៅ ហើយក៏ខំមមុលឈោងទៅសេចក្តីខាងមុខទៀត›។ នៅក្នុងខ១៥លោកប៉ុលថា យើងទាំងអស់គ្នា ដែលគ្រប់លក្ខណ៍ ត្រូវមានគំនិតយ៉ាងនេះ។ **ការអនុវត្តន៍ និង ការជញ្ជឹងគិត** តើអ្នកមានអាកប្បកិរិយាដូចប៉ុលត្រង់ចំណុចនេះមែនឬទេ? បើសិនទេ តើអ្នកត្រូវផ្លាស់ប្តូរយ៉ាងម៉េចដើម្បីឲ្យមានគំនិតដូចជាលោកប៉ុល?

សូមអានខ១៧។

នៅក្នុងខនេះយើងឃើញថា គ្រីស្ទបរិស័ទដែលមានការទទួលខុសត្រូវធ្វើជាអ្នកដឹកនាំត្រូវផ្តល់គំរូល្អនៃជីវិតរបស់ខ្លួន។ តាមរយៈខនេះ តើលោកប៉ុលទូន្មានគ្រីស្ទបរិស័ទឲ្យធ្វើអ្វី?

សូមអានខ១៨-១៩។

តើខ្មាំងសត្រូវនឹងឈើឆ្កាងរបស់ព្រះគ្រីស្ទបានគិតពីអ្វីខ្លះ?

លទ្ធផលចុងក្រោយនៃខ្មាំងសត្រូវនឹងឈើឆ្កាងរបស់ព្រះគ្រីស្ទគឺជាអ្វី?

សូមអាន និងសង្ខេប ខ២០-២១។

**ការជញ្ជឹងគិត និង ការជជែកគ្នា** តើ ខ២០-២១ បានលើកទឹកចិត្តអ្នកយ៉ាងម៉េចដែរ?

**រំលឹកឡើងវិញ** តើអ្នកបានរៀនអ្វីខ្លះចេញពី ភីលីព ៣:១២-២១នេះ?

**ការអនុវត្តន៍ និង ជជែកគ្នា** អ្វីដែលយើងបានរៀនតាមរយៈបទគម្ពីរខាងលើនេះ តើយើងត្រូវយកវាមកអនុវត្តន៍ចំពោះខ្លួនអ្នកយ៉ាងដូចម្ដេចនាពេលសព្វថ្ងៃនេះ?
តើអ្នកត្រូវមានការផ្លាស់ប្តូរជីវិតយ៉ាងម៉េចតាមរយៈមេរៀនចេញពីអត្ថបទនេះ?